**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

*ថ្ងៃ ពុធ ១ កើត ខែ ពិសាខ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
## ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និង ប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ"

នាព្រឹកថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០២៤, នៅសណ្ឋាគារសុខាភ្នំពេញ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធី "**ប្រកាសដាក់ឱ្យអនុវត្តគម្រោង** FMIS **ទៅកាន់ការដ្ឋានបន្ថែមថ្មី និង ប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ**" ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងតំណាងដៃគូអភិវឌ្ឍ សរុបប្រមាណ ៤០០ រូប ។

មកដល់បច្ចុប្បន្ននេះ, FMIS (Financial Management Information System) ត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់ទីតាំងអនុវត្តថវិកាសំខាន់ៗ ទាំងនៅថ្នាក់ជាតិ និងទាំងនៅថ្នាក់ក្រោមជាតិ រួមមាន អគ្គនាយកដ្ឋានជំនាញទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅគ្រប់ក្រសួង-ស្ថាប័ន, មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥, រតនាគាររាជធានី-ខេត្តទាំង ២៥, រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ និងរដ្ឋបាលក្រុង-ស្រុក-ខណ្ឌចំនួន ៤៤ ដែលសរុប មានចំនួន ២១៣ ការដ្ឋាន ។ ជាមួយគ្នានេះ, ការដាក់ឱ្យប្រើប្រាស់ FMIS Portal ជំនាន់ទី ១ នៅគ្រប់រដ្ឋបាលក្រុង-ស្រុក និងឃុំ-សង្កាត់ នៅទូទាំងប្រទេសកម្ពុជា សរុបចំនួន ១,៨៧០ ការដ្ឋាន ។

ស្របពេលដែលរាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់ ***សម្តេចមហាបវរធិបតី* ហ៊ុន ម៉ាណែត** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមគ្គុទេសក៍វៃក្លេងដ៏ឆ្នើម,* បានដាក់ចេញនូវ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ដោយបន្ថែម បច្ចេកវិទ្យា ជាពិសេស គឺ បច្ចេកវិទ្យាឌីជីថល ជាអាទិភាពគន្លឹះថ្មី សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា, រហូតមកទល់ពេលនេះ តាមរយៈវិសាលភាពនៃការប្រើប្រាស់ FMIS, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាច្រើនរូប ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ និងថវិកា បានយល់ដឹង ចូលរួមចំណែក និងទទួលយកនូវការងារតាមរបៀបថ្មីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្ទើរតែទូទាំងប្រទេស ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី គូសបញ្ជាក់ថា *"ការអនុវត្តផែនការយុទ្ធសាស្ត្រ តម្រង់ទិសនីតិវិធីអនុវត្តការងារតាម FMIS បាន និងកំពុងបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីប្រសិទ្ធភាពដ៏ធំធេង ក្នុងការកសាងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ការចាត់ចែង និងការបែងចែកធនធានហិរញ្ញវត្ថុជាតិ ឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ចូលរួមចំណែកជួយគាំទ្រដល់ការឈានទៅសម្រេចបាន តាមចក្ខុវិស័យនៃការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០"* និងបានប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ក៏ដូចជាប្រើប្រាស់សមិទ្ធផលថ្មីៗ ដូចខាងក្រោម÷

**១-ការដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្មីចំនួន ៥** រួមមាន÷ សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យជាតិបាត់ដំបង, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដោយប្រើប្រាស់នីតិវិធីចំណាយ និងចលនាឥណទានថវិកាចរន្តតាម FMIS ទាំងស្រុង ។

**២-ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS នៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្តាលចំនួន ៤៤ នៃក្រសួង-ស្ថាប័នចំនួន ១០** រួមមាន÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងយុត្តិធម៌, ក្រសួងរ៉ែ និងថាមពល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, អាជ្ញាធរសវនកម្មជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយប្រើប្រាស់នីតិវិធីចំណាយ និងចលនាឥណទានថវិកាចរន្តតាម FMIS ទាំងស្រុង ។

**៣-ប្រកាសដាក់ឱ្យអនុវត្តនីតិវិធីចលនាឥណទានថវិកាចរន្តតាម FMIS ទាំងស្រុង នៅក្រសួង-ស្ថាប័នចំនួន ៨** រួមមាន÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន, ក្រសួងរ៉ែ និងថាមពល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, អាជ្ញាធរសវនកម្មជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងយុត្តិធម៌ ។

**៤-ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មុខងារតាមដានប្រតិបត្តិការ និងស្ថានភាពអនុម័តប្រតិបត្តិការ (FMIS Transaction Monitoring)** នៅគ្រប់ការដ្ឋាន FMIS ទាំងអស់ និង**មុខងារតាមដាន និងត្រួតពិនិត្យការអនុវត្តថវិកា (FMIS Performance Monitoring)** នៅការដ្ឋាន FMIS ដែលអនុវត្តនីតិវិធីអនុវត្តការងារតាម FMIS ទាំងស្រុង ។

**៥-ប្រកាសដាក់ឱ្យប្រើប្រាស់របាយការណ៍ស្តង់ដាររួមនៅក្នុង FMIS** រួមមាន របាយការណ៍ចំណាយថវិកាថ្នាក់ជាតិ ដែលមានលេខកូដ R87 និងរបាយការណ៍សរុបចំណូល និងចំណាយថវិកាថ្នាក់ក្រោមជាតិ ដែលមានលេខកូដ R83 ; និង

**៦-ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS នៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្តាលចំនួន ៤** នៃក្រសួងធនធានទឹក និងឧតុនិយម ។